លេខ ៣៦ ចេញផ្សាយថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែឧសភា ឆ្នាំ២០២៤

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៩រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ និយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) និងវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យបានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **លោក ម៉ិន សុន្ទរឋ** នាយកនៃវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ នៅវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅវិទ្យាស្ថាន អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, តំណាងធនាគារកាណាឌីយ៉ា ក.អ និងនិស្សិតនៃវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ។

## មាតិកា

❖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី១
❖ កិច្ចពិភាក្សារវាង **ន.ប.ធ.** ជាមួយសភាពាណិជ្ជកម្មចិន (កម្ពុជា) ទំព័រទី២
❖ កិច្ចប្រជុំពិភាក្សាការងារជាមួយអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំព័រទី២
❖ កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទំព័រទី៣
❖ សិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៤-២០៣៣)" ទំព័រទី៣
❖ កិច្ចប្រជុំក្រុមការងារបច្ចេកទេសទី១ នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ទំព័រទី៣
❖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" ទំព័រទី៤
❖ ពិធី "ប្រកាសដាក់ឱ្យអនុវត្តគម្រោង FMIS ទៅកាន់ការដ្ឋានបន្ថែមថ្មី និងប្រើប្រាស់សមិទ្ធផលថ្មីៗជាផ្លូវការ" ទំព័រទី៤
❖ កិច្ចប្រជុំ ក្រោមប្រធានបទស្តីពី "និយ័តករបរធនបាលកិច្ច និងបច្ចុប្បន្នភាពគតិយុត្ត" ទំព័រទី៥
❖ កិច្ចពិភាក្សាការងារជាមួយគណៈប្រតិភូដែលជាថ្នាក់ដឹកនាំនៃសមាគម និងក្រុមហ៊ុនដែលឈានមុខមកពីទីក្រុងសិនជិននៃសាធារណរដ្ឋប្រជាមានិតចិន ទំព័រទី៥
❖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" ទំព័រទី៥
❖ កិច្ចប្រជុំអន្តរអង្គភាពចំណុះឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំព័រទី៦
❖ ការផ្សព្វផ្សាយការងារពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍ ទំព័រទី៦
❖ សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" ទំព័រទី៧
❖ កិច្ចប្រជុំលើកទី១ របស់ក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ទំព័រទី៧
❖ ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍ស្តីពីក្របខណ្ឌបទប្បញ្ញត្តិ ការអភិវឌ្ឍទីផ្សារ ផលិតផលបរធនបាលកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច នៅសាធារណរដ្ឋកូរ៉េ ទំព័រទី៨
❖ កិច្ចពិភាក្សារវាង ន.ប.ធ. និងប្រតិភូសភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា ទំព័រទី៩
❖ កិច្ចពិភាក្សារវាង ន.ប.ធ. និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ទំព័រទី៩
❖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំស្តីពី ទម្រង់របាយការណ៍របស់បរធនបាល" ទំព័រទី៩
❖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី១០
❖ កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទំព័រទី១០
❖ ពិធីដាក់ឱ្យដំណើរការកញ្ចប់ហិរញ្ញវត្ថុគាំទ្រវិនិយោគ ទំព័រទី១០
❖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទំព័រទី១១
❖ សិក្ខាសាលាបណ្តុះបណ្តាលស្តីពី "បទដ្ឋានអន្តរជាតិ និងច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មសម្រាប់និយ័តករ និងបុគ្គលរាយការណ៍" ទំព័រទី១១



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




**រូបភាព៖** សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## កិច្ចពិភាក្សារវាង ន.ប.ធ. ជាមួយសភាពាណិជ្ជកម្មចិន (កម្ពុជា)

នាព្រឹកថ្ងៃព្រហស្បតិ៍ ៩រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណឹ សាកល** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញទទួលជួបសម្តែងការគួរសមជាមួយសភាពាណិជ្ជកម្មចិន (កម្ពុជា) ដឹកនាំដោយ **លោក Zhao Jinhui** អនុប្រធានប្រចាំការ និងជាអគ្គលេខាធិការនៃសភាពាណិជ្ជកម្មចិន (កម្ពុជា) និងមានការចូលរួមពីប្រតិភូសភាពាណិជ្ជកម្មចិន (កម្ពុជា) សាខាខេត្តសៀមរាបផងដែរ ក្នុងគោលបំណងដើម្បីឈ្វេងយល់ និងពិភាក្សាពីបច្ចុប្បន្នភាពនៃទីផ្សារបរធនបាលកិច្ចនៅកម្ពុជា, ក្របខណ្ឌច្បាប់, កាលានុវត្តភាពនៃការវិនិយោគតាមរយៈយន្តការបរធនបាលកិច្ច និងកិច្ចសហប្រតិបត្តិការដែលអាចនឹងកើតមាននាពេលអនាគត នៅទីស្តីការ **ន.ប.ធ.**។




**រូបភាព៖** កិច្ចពិភាក្សារវាង **ន.ប.ធ.** ជាមួយសភាពាណិជ្ជកម្មចិន (កម្ពុជា។

## កិច្ចប្រជុំពិភាក្សាការងារជាមួយអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នារសៀលថ្ងៃព្រហស្បតិ៍ ៩រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំក្រុមការងាររៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៤-២០៣៣) ជួបប្រជុំពិភាក្សាការងារជាមួយអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលដឹកនាំដោយ **ឯកឧត្តម អ៊ុច លុយណា** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អមដោយសហការី។ កិច្ចប្រជុំបានផ្តោតការពិភាក្សាអំពីទស្សនទានទិសដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច គោលនយោបាយក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្នុងក្របខណ្ឌវិស័យ ក៏ដូចជាការគ្រប់គ្រងការត្រួតពិនិត្យ និងការការពារហានិភ័យ ព្រមទាំងការចូលរួមនៃយន្តការបរធនបាលកិច្ចក្នុងគម្រោងសាធារណៈ និងឯកជនពាក់ព័ន្ធមួយចំនួនផងដែរ។




**រូបភាព៖** កិច្ចប្រជុំពិភាក្សាការងារជាមួយអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh   www.facebook.com/trustregulatorcambodia   (855) 23 237 888

## កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

នាព្រឹកថ្ងៃសុក្រ ១០រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំក្រុមការងាររៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៤-២០៣៣) ជួបប្រជុំពិភាក្សាការងារជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលដឹកនាំដោយ **ឯកឧត្តម តឹករ៉េត សំរេច** រដ្ឋលេខាធិការប្រចាំការ អមដោយឯកឧត្តម ប្រាក់អង្គារ៉ា អគ្គនាយកនៃអគ្គនាយកដ្ឋានលំនៅឋាន និងសហការី។ កិច្ចប្រជុំបានផ្តោតការពិភាក្សាអំពីបច្ចុប្បន្នភាពនៃទីផ្សារបរធនបាលកិច្ច ការចូលរួមចំណែករបស់យន្តការបរធនបាលកិច្ច ដែលរួមទាំងសេវារក្សាសុវត្ថិភាព ឬរក្សាទុក (Escrow Services) ក្នុងការអភិវឌ្ឍវិស័យអចលនទ្រព្យនៅកម្ពុជា ក៏ដូចជាបញ្ហាប្រឈមពាក់ព័ន្ធក្នុងការអនុវត្ត និងទិសដៅការងាររួមគ្នាមួយចំនួនផងដែរ។




**រូបភាព៖** កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## សិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៤-២០៣៣)"

នារសៀលថ្ងៃសុក្រ ១០រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៤-២០៣៣)" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង និងប្រធាននាយកដ្ឋាន ព្រមទាំងមន្ត្រីជំនាញនៃ **ន.ប.ធ.** ដែលមានការចូលរួមពីក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គលប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច ដើម្បីទទួលបានមតិយោបល់ និងធាតុចូលបន្ថែមពីតួអង្គ និងភាគីពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ដើម្បីឱ្យការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ កាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ សំដៅដល់ការអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធភាព និងទំនុកចិត្តពីអ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច នៅទីស្តីការរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ កម្មវិធីនេះត្រូវបានបញ្ចប់ទៅដោយរលូន និងប្រកបដោយផ្លែផ្កាក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។




**រូបភាព៖** សិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៤-២០៣៣)"។

## កិច្ចប្រជុំក្រុមការងារបច្ចេកទេសទី១ នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

នារសៀលថ្ងៃចន្ទ ១៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសទី១ នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់

**ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.**។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមដោយ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិក-សមាជិកា នៃក្រុមការងារ។



**រូបភាព៖** កិច្ចប្រជុំក្រុមការងារបច្ចេកទេសទី១ នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍"

ចាប់ពីថ្ងៃអង្គារ ១៤រោច ខែចេត្រ ដល់ថ្ងៃព្រហស្បតិ៍ ២ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី៧-៩ ខែឧសភា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP PIU1, **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 បានដឹកនាំក្រុមការងារ រៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" នៅខេត្តឧត្តរមានជ័យ។ កម្មវិធីនេះត្រូវបានរៀបចំនៅសហគមន៍ចំនួន ៥ រួមមាន៖ **១.**សហគមន៍លំទងសាមគ្គីអភិវឌ្ឍន៍,**២.**សហគមន៍ភូមិខ្ញុំ, **៣.**សហគមន៍រន្លីថ្មីផ្អុង, **៤.**សហគមន៍គោកមនមានជ័យ និង **៥.**សហគមន៍គោកឪឡោក នៅខេត្តឧត្តរមានជ័យ។ កម្មវិធីនេះត្រូវបានរៀបចំក្នុងគោលបំណងធ្វើការណែនាំបន្ថែមដល់សមាជិកសហគមន៍ និងភ្នាក់ងារឥណទានគម្រោង ACSEP តាមខេត្ត ស្រុក និងឃុំគោលដៅ, ផ្តល់ព័ត៌មានអំពីការផ្តល់ប្រាក់កម្ចី របស់ គម្រោង ACSEP ដល់សមាជិកសហគមន៍កសិកម្មដែលមានក្នុងបញ្ជីក្រុមគោលដៅ និងកសិករចិញ្ចឹមមាន់ស្រុក និងបង្ហាញអំពីនីតិវិធីដែលអាចទទួលបានឥណទានដល់សមាជិកសហគមន៍កសិកម្ម ដែលមានបំណងស្វែងរកទុនគាំទ្រផែនការអាជីវកម្មលើវិស័យកសិកម្ម។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងអគ្គនាយកដ្ឋានកសិកម្ម និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមានធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



**រូបភាព៖** សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍"។

## ពិធី "ប្រកាសដាក់ឱ្យអនុវត្តគម្រោង FMIS ទៅកាន់ការដ្ឋានបន្ថែមថ្មី និងប្រើប្រាស់សមិទ្ធផលថ្មីៗជាផ្លូវការ"

នាព្រឹកថ្ងៃពុធ ១កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែឧសភាឆ្នាំ២០២៤ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមពិធី "ប្រកាសដាក់ឱ្យអនុវត្តគម្រោង FMIS ទៅកាន់ការដ្ឋានបន្ថែមថ្មី និងប្រើប្រាស់សមិទ្ធផលថ្មីៗជាផ្លូវការ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានការចូលរួមពី **ឯកឧត្តម ឌៀសម៉ាន់** អីហ្គោរ៍ (Diesmans Igor) ឯកអគ្គរដ្ឋទូតប្រតិភូសហភាពអឺរ៉ុប និងជាតំណាងដៃគូអភិវឌ្ឍន៍, ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅសណ្ឋាគារសុខា ភ្នំពេញ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាព៖ ពិធី "ប្រកាសដាក់ឱ្យអនុវត្តគម្រោង FMIS ទៅកាន់ការដ្ឋានបន្ថែមថ្មី និងប្រើប្រាស់សមិទ្ធផលថ្មីៗជាផ្លូវការ"។

## កិច្ចប្រជុំ ក្រោមប្រធានបទស្តីពី "និយ័តករបរធនបាលកិច្ច និងបច្ចុប្បន្នភាពគតិយុត្ត"

នារសៀលថ្ងៃពុធ ១កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសភាពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជា (IBC) បានរៀបចំកិច្ចប្រជុំ ក្រោមប្រធានបទស្តីពី "និយ័តករបរធនបាលកិច្ច និងបច្ចុប្បន្នភាពគតិយុត្ត" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **លោក** Paul Clements, ប្រធានសភាពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជា ក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងអំពីបច្ចុប្បន្នភាពនៃទីផ្សារបរធនបាលកិច្ចនៅកម្ពុជា, ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ, កាលានុវត្តភាពនៃការវិនិយោគតាមរយៈយន្តការបរធនបាលកិច្ច និងគុណប្រយោជន៍នៃយន្តការបរធនបាលកិច្ចដល់ថ្នាក់ដឹកនាំ និងសមាជិក-សមាជិកានៃIBC នៅសណ្ឋាគារ រ៉ាហ្វិល ឡឺរ៉ូយ៉ាល់។




រូបភាព៖ កិច្ចប្រជុំ ក្រោមប្រធានបទស្តីពី "និយ័តករបរធនបាលកិច្ច និងបច្ចុប្បន្នភាពគតិយុត្ត"។

## កិច្ចពិភាក្សាការងារជាមួយគណៈប្រតិភូដែលជាថ្នាក់ដឹកនាំនៃសមាគម និងក្រុមហ៊ុនដែលឈានមុខមកពីទីក្រុងសិនជិននៃសាធារណរដ្ឋប្រជាមានិតចិន

នារសៀលថ្ងៃពុធ ១កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ឈី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូដែលជាថ្នាក់ដឹកនាំនៃសមាគម និងក្រុមហ៊ុនដែលឈានមុខមកពីទីក្រុងសិនជិននៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងគោលបំណងដើម្បីឈ្វេងយល់ និងពិភាក្សាពីបច្ចុប្បន្នភាពនៃទីផ្សារបរធនបាលកិច្ចនៅកម្ពុជា, ក្របខណ្ឌច្បាប់, កាលានុវត្តភាពនៃការវិនិយោគតាមរយៈយន្តការបរធនបាលកិច្ច និងកិច្ចសហប្រតិបត្តិការដែលអាចនឹងកើតមាននាពេលអនាគត នៅទីស្តីការ **ន.ប.ធ.**។




រូបភាព៖ កិច្ចពិភាក្សាការងារជាមួយគណៈប្រតិភូដែលជាថ្នាក់ដឹកនាំនៃសមាគម និងក្រុមហ៊ុនដែលឈានមុខមកពីទីក្រុងសិនជិននៃសាធារណរដ្ឋប្រជាមានិតចិន។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍"

នាថ្ងៃពុធ ១ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP PIU1, **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 បានដឹកនាំក្រុមការងារ រៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" នៅខេត្តឧត្តរមានជ័យ។

កម្មវិធីនេះត្រូវបានរៀបចំនៅសហគមន៍ចំនួន ២ រួមមាន៖ **១.**សហគមន៍ភូមិខ្ញុំ, **២.**សហគមន៍រន្លីថ្មីផ្លុង នៅខេត្តឧត្តរមានជ័យ។ កម្មវិធីនេះត្រូវបានរៀបចំក្នុងគោលបំណងធ្វើការណែនាំបន្ថែមដល់សមាជិកសហគមន៍ និងភ្នាក់ងារឥណទានគម្រោង ACSEP តាមខេត្ត ស្រុក និងឃុំគោលដៅ, ផ្តល់ព័ត៌មានអំពីការផ្តល់ប្រាក់កម្ចី របស់គម្រោង ACSEP ដល់សមាជិកសហគមន៍កសិកម្មដែលមានក្នុងបញ្ជីក្រុមគោលដៅ និងកសិករចិញ្ចឹមមាន់ស្រុក និងបង្ហាញអំពីនីតិវិធីដែលអាចទទួលបានឥណទានដល់សមាជិកសហគមន៍កសិកម្ម ដែលមានបំណងស្វែងរកទុនគាំទ្រផែនការអាជីវកម្មលើវិស័យកសិកម្ម។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, តំណាងអគ្គនាយកដ្ឋានកសិកម្ម និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។




រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍"។

## កិច្ចប្រជុំអន្តរអង្គភាពចំណុះឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នារសៀលថ្ងៃព្រហស្បតិ៍ ២កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** អមដោយ **លោកស្រី ឈាន សុខាវី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងសហការី បានចូលរួមកិច្ចប្រជុំអន្តរអង្គភាព ចំណុះឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) និងនិយ័តករពាក់ព័ន្ធនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមការដឹកនាំរបស់ **ឯកឧត្តម ស៊ាង ផល្លា** អនុរដ្ឋលេខាធិការ កសហវ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល ចេញ និងស្នាក់នៅព្រះរាជាណាចក្រកម្ពុជា ។




រូបភាព៖ កិច្ចប្រជុំអន្តរអង្គភាពចំណុះឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ការផ្សព្វផ្សាយការងារពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍

កាលពីថ្ងៃព្រហស្បតិ៍ ២ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្រោមក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបន្តការងារផ្សព្វផ្សាយពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍ គោកមនមានជ័យ និងសហគមន៍គោកឪឡោក នៅខេត្តឧត្តរមានជ័យ។

កម្មវិធីនេះត្រូវបានរៀបចំក្នុងគោលបំណងធ្វើការណែនាំបន្ថែមដល់សមាជិកសហគមន៍ និងភ្នាក់ងារឥណទានគម្រោង ACSEP តាមខេត្ត ស្រុក និងឃុំគោលដៅ, ផ្តល់ព័ត៌មានអំពីការផ្តល់ប្រាក់កម្ចីរបស់គម្រោង ACSEP ដល់សមាជិកសហគមន៍កសិកម្មដែលមានក្នុងបញ្ជីក្រុមគោលដៅ និងកសិករចិញ្ចឹមមាន់ស្រុក និងបង្ហាញអំពីនីតិវិធីដែលអាចទទួលបានឥណទានដល់សមាជិកសហគមន៍កសិកម្ម ដែលមានបំណងស្វែងរកទុនគាំទ្រផែនការអាជីវកម្មលើវិស័យកសិកម្ម។

កម្មវិធីខាងលើ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រុមប្រឹក្សាឃុំ, មេភូមិ, ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ ការផ្សព្វផ្សាយការងារពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍។

## សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"

នារសៀលថ្ងៃសៅរ៍ ៤កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៤ និយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) និងរាជបណ្ឌិត្យសភាកម្ពុជា បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **លោកបណ្ឌិត វង់ សំអូន** អនុប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជា។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតអំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខា-សាលានេះក៏បានផ្តល់ឱកាសដល់និស្សិត ដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ, និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតនៃរាជបណ្ឌិត្យសភាកម្ពុជា។



រូបភាព៖ ការផ្សព្វផ្សាយការងារពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍។

## កិច្ចប្រជុំលើកទី១ របស់ក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

នាព្រឹកថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម ឈឺ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី១ របស់ក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលបានប្រព្រឹត្តទៅនៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមដោយផ្ទាល់ពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិក-សមាជិកា នៃក្រុមការងារ។



រូបភាព៖ កិច្ចប្រជុំលើកទី១ របស់ក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

## ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍ស្តីពីក្របខណ្ឌបទប្បញ្ញត្តិ ការអភិវឌ្ឍទីផ្សារ ផលិតផលបរធនបាលកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច នៅសាធារណរដ្ឋកូរ៉េ

ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), ចាប់ពីថ្ងៃទី១៥-១៧ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ, **លោកស្រី ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងសហការីនៃ **ន.ប.ធ.** បានដឹកនាំធ្វើទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍ស្តីពីក្របខណ្ឌបទប្បញ្ញត្តិ ការអភិវឌ្ឍទីផ្សារ ផលិតផលបរធនបាលកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច នៅសាធារណរដ្ឋកូរ៉េ និងបានពិភាក្សាការងារពាក់ព័ន្ធ ជាមួយគណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ (Financial Services Commission-FSC), ទីភ្នាក់ងារសេវាត្រួតពិនិត្យហិរញ្ញវត្ថុកូរ៉េ (Financial Supervisory Service-FSS), សមាគមវិនិយោគហិរញ្ញវត្ថុកូរ៉េ (Korea Financial Investment Association-KOFIA), ក្រុមហ៊ុន KB Real Estate Trust, វិទ្យាស្ថានកូរ៉េនៃឧស្សាហកម្មហិរញ្ញវត្ថុ (Korea Institute of Finance Industry-KIFI) ព្រមទាំងជាមួយនាយក និងសាស្ត្រាចារ្យនៃវិទ្យាស្ថាន KAIST (Korea Advanced Institute of Science and Technology) ក្រោមការសម្របសម្រួលពីក្រុមហ៊ុន អេសអិម គ្លូបិលត្រាស់ & អ៊ិនវេសមេន មេណេជឺមេន ឯ.ក ដែលជាក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.**។













*រូបភាព៖* ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍ស្តីពីក្របខណ្ឌបទប្បញ្ញត្តិ ការអភិវឌ្ឍទីផ្សារ ផលិតផលបរធនបាលកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច នៅសាធារណរដ្ឋកូរ៉េ។

## កិច្ចពិភាក្សារវាង ន.ប.ធ. និងប្រតិភូសភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា

នារសៀលថ្ងៃអង្គារ ១៤កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានទទួលជួបប្រតិភូសភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា ដឹកនាំដោយ **លោក An Kio** ប្រធាននៃសភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា អមដោយ **លោក Brian Ko** អនុប្រធាននៃសភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា និងសហការី ដោយបានពិភាក្សាលើក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិ កិច្ចដំណើរការអភិវឌ្ឍន៍ទីផ្សារបរធនបាលកិច្ច កាលានុវត្តភាព និងលទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការ ក្នុងក្របខណ្ឌបច្ចេកទេស ពាក់ព័ន្ធនឹងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមក្នុងទីផ្សារបរធនបាលកិច្ចនៅកម្ពុជា នៅទីស្តីការនិយ័តករបរធនបាលកិច្ច។




រូបភាព៖ កិច្ចពិភាក្សារវាង ន.ប.ធ. និងប្រតិភូសភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា។

## កិច្ចពិភាក្សារវាង ន.ប.ធ. និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

នាព្រឹកថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោកស្រី ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងសហការី បានជួបពិភាក្សាជាមួយ **ឯកឧត្តម ហេង ប៊ុមគា** ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អំពីការពង្រឹងកិច្ចសហការរវាងអង្គភាពស៊ើបការហិរញ្ញវត្ថុកម្ពុជា និងនិយ័តករបរធនបាលកិច្ច ដើម្បីលើកកម្ពស់ការពិនិត្យអនុលោមភាព និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ក្នុងវិស័យបរធនបាលកិច្ច។



រូបភាព៖ កិច្ចពិភាក្សារវាង ន.ប.ធ. និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំ ស្តីពី ទម្រង់របាយការណ៍របស់បរធនបាល"

នៅរសៀលថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំ ស្តីពី ទម្រង់របាយការណ៍របស់បរធនបាល" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីបញ្ជ្រាបការយល់ដឹងដល់បរធនបាលដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.** ក្នុងការបំពេញកាតព្វកិច្ចផ្តល់របាយការណ៍របស់បរធនបាល សំដៅដល់ការអនុវត្តប្រកបដោយសង្គតិភាព សណ្តាប់ធ្នាប់ និងប្រសិទ្ធភាព។ សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ព្រមទាំងថ្នាក់ដឹកនាំ និងតំណាងក្រុមហ៊ុនបរធនបាល, ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (ធនាគារពាណិជ្ជ) និងបរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.**។




រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំ ស្តីពី ទម្រង់របាយការណ៍របស់បរធនបាល"។

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃចន្ទ ៥រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យបៀលប្រាយ ខេត្តបាត់ដំបង បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង **លោកស្រី ឈឿន ចាន់ណា** នាយិការងសាខានៃសាកលវិទ្យាល័យបៀលប្រាយ ខេត្តបាត់ដំបង នៅទីតាំងសាកលវិទ្យាល័យបៀលប្រាយ ខេត្តបាត់ដំបង។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, **លោក ស៊ីយ៉ា ម៉ាលីជា** នាយកការិយាល័យប្រតិបត្តិការមូលបត្រនិង បរធនបាលកិច្ច វាគ្មិនតំណាងពីធនាគារអេស៊ីលីដា ភីអិលស៊ី, សាស្ត្រាចារ្យ, និងនិស្សិតនៃសាកលវិទ្យាល័យបៀលប្រាយ ខេត្តបាត់ដំបង។



រូបភាព៖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នាព្រឹកថ្ងៃពុធ ៧រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក យុន វ៉ាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័នអង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ"។

## ពិធីដាក់ឱ្យដំណើរការកញ្ចប់ហិរញ្ញវត្ថុគាំទ្រវិនិយោគ

នាព្រឹកថ្ងៃពុធ ៦ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាតំណាងអង្គភាពអនុវត្តគម្រោង ACSEP សម្រាប់សមាសភាគទី១ អមដោយសហការី បានអញ្ជើញចូលរួមនៅក្នុង "ពិធីដាក់ឱ្យដំណើរការកញ្ចប់ហិរញ្ញវត្ថុគាំទ្រវិនិយោគ" ក្រោមអធិបតីភាព



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង **ឯកឧត្តម អ៊ីហ្គោរ៍ ឌ្រីសម៉ាន់** ឯកអគ្គរដ្ឋទូត សហភាពអឺរ៉ុប ប្រចាំប្រទេសកម្ពុជា ដែលសហការរៀបចំដោយ CGCC និង UNIDO (United Nations Industrial Develop Organization) នៅសណ្ឋាគារ សូហ្វីតែលភ្នំពេញភូគីត្រា។ កិច្ចប្រជុំនេះមានការចូលរួមពីតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រតិភូសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជា វិស័យឯកជន អង្គការជាតិ និងអន្តរជាតិ I/NGOs វិទ្យាស្ថានសិក្សានិងស្រាវជ្រាវ និងសមាគមអាជីវកម្ម។



រូបភាព៖ ពិធីដាក់ឱ្យដំណើរការកញ្ចប់ហិរញ្ញវត្ថុគាំទ្រវិនិយោគ។

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃព្រហស្បត្ត៍ ៨រោចខែពិសាខឆ្នាំរោងបញ្ចស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច អមដោយសហការីបានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) លើសេចក្តីព្រាងច្បាប់ស្តីពី "អាជីវកម្ម និងសេវាកម្មអចលនវត្ថុ" ដែលរៀបចំដោយនិយ័តករអចលនវត្ថុ និងបញ្ចាំ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## សិក្ខាសាលាបណ្តុះបណ្តាលស្តីពី "បទដ្ឋានអន្តរជាតិ និងច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម សម្រាប់និយ័តករ និងបុគ្គលរាយការណ៍"

នារសៀលថ្ងៃព្រហស្បតិ៍ ៨ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ឆែម លាបហេង** ប្រធានការិយាល័យអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់ តំណាង **ន.ប.ធ.** និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ព្រមទាំងមានការចូលរួមពីបុគ្គលរាយការណ៍នៃក្រុមហ៊ុនបរធនបាល ក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពី "បទដ្ឋានអន្តរជាតិ និងច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម សម្រាប់និយ័តករ និងបុគ្គលរាយការណ៍" ដែលរៀបចំដោយធនាគារជាតិនៃកម្ពុជា (សែនសុខ) ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ហេង បូមករា** ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ព្រមទាំងវាគ្មិនពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាតំណាងនិយ័តករមូលបត្រកម្ពុជា, និយ័តករធានារ៉ាប់រងកម្ពុជា, និយ័តករសន្តិសុខសង្គម និងនិយ័តករគណនេយ្យករនិងសវនកម្ម សរុបចំនួន ៨៩ រូប។



រូបភាព៖ សិក្ខាសាលាបណ្តុះបណ្តាលស្តីពី "បទដ្ឋានអន្តរជាតិ និងច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម សម្រាប់និយ័តករ និងបុគ្គលរាយការណ៍"។